# របាយការណ៍លទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣
# របស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តបន្ទាយមានជ័យ

## សេចក្តីផ្តើម

ខេត្តបន្ទាយមានជ័យ ស្ថិតនៅទិសពាយ័ព្យនៃព្រះរាជាណាចក្រកម្ពុជា ជាតំបន់ព្រំដែនជាប់ប្រទេសថៃ មានចម្ងាយប្រមាណជា ៣៦៩គ.ម ពីរាជធានីភ្នំពេញ តាមផ្លូវជាតិលេខ៥ មានផ្ទៃដីសរុបចំនួន ៦,៦៧៩ គីឡូម៉ែត្រក្រឡា មានផ្លូវជាតិឆ្លងកាត់ចំនួន ៦ខ្សែ គឺផ្លូវជាតិលេខ៥ ផ្លូវជាតិលេខ៦ ផ្លូវជាតិលេខ៥៦ ផ្លូវជាតិលេខ៥៨ ផ្លូវជាតិលេខ៥៩ និងផ្លូវជាតិលេខ៥៦D ព្រមទាំងមានផ្លូវរថភ្លើងឆ្លងកាត់ ១ខ្សែ។ ខេត្តបន្ទាយមានជ័យមានព្រំប្រទល់ខាងលិចជាប់នឹងប្រទេសថៃ ក្នុងនោះក្រុងស្រុកចំនួន៥ជាប់តាមបណ្តោយព្រំដែនថៃ មានស្រុកម៉ាឡៃ ស្វាយចេក អូរជ្រៅ ថ្មពួក និងក្រុងប៉ោយប៉ែត ខាងជើងជាប់នឹងខេត្តឧត្តរមានជ័យ ខាងកើតជាប់ខេត្តសៀមរាប និងខាងត្បូងជាប់នឹងខេត្តបាត់ដំបង។ រដ្ឋបាលខេត្តបន្ទាយមានជ័យចែកចេញជាក្រុង២ (ក្រុងសិរីសោភ័ណ និងក្រុងប៉ោយប៉ែត) និងស្រុកចំនួន៧ (ស្រុកថ្មពួក ស្វាយចេកអូរជ្រៅមង្គលបូរី ព្រះនេត្រព្រះ ម៉ាឡៃ និងស្រុកភ្នំស្រុក) មានសង្កាត់ចំនួន១២ ឃុំចំនួន៥៥ និងភូមិចំនួន ៦៧០ភូមិ (គិតទាំងភូមិបង្កើតថ្មីមិនទាន់ទទួលស្គាល់ជាផ្លូវការចំនួន ១២ភូមិ) មានប្រជាពលរដ្ឋចំនួន១៨៨,៣៦៨គ្រួសារ និងមានប្រជាជនសរុប ៨៣៥,៤១៩នាក់ ក្នុងនោះស្ត្រីចំនួន ៣៨៣,០៥២នាក់ ហើយស្ថានភាពផ្ទៃដីចែកជាភ្នំ ស្ទឹង ខ្ពង់រាប និងទំនាប ប្រជាពលរដ្ឋប្រមាណជា ៨០ភាគរយ ជាកសិករធ្វើស្រែ ចម្ការ ក្រៅពីនោះជាមន្ត្រីរាជការ អាជីវករ អ្នកនេសាទ និងសិប្បកម្មតូចតាច។

## I.សមិទ្ធផលសម្រេចបាន

### ១.ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាព

**+ការងាររដ្ឋបាល និងបុគ្គលិក**

មន្ទីរមានមន្ត្រីរាជការសរុបចំនួន ៣១រូប ស្ត្រីចំនួន០៩រូប ដឹកនាំដោយប្រធានមន្ទីរ ០១រូប និងអនុប្រធានមន្ទីរ ០៤រូប(ស្ត្រី ០១រូប) ក្នុងនោះមានការិយាល័យជំនាញ ចំនួន១០ ។

- លិខិតចូលពីបណ្តាអង្គការនានាក្រោមន្ទីរចំនួន ៣៣៦លិខិត
- លិខិតចូលពីក្រសួងសាមី និងចំណុះមន្ទីរចំនួន ៧១លិខិត
- លិខិតចេញទៅបណ្តាអង្គភាពនានាក្រោមន្ទីរចំនួន ២៤៥លិខិត
- លិខិតចេញពាក់ព័ន្ធស្ថានភាពមន្ត្រីរាជការចំនួន ២៧លិខិត
- លិខិតចេញទូទៅចំនួន ៦៣លិខិត
- លិខិតចេញទៅបណ្តាអង្គភាពនានាក្រោមឱវាទមន្ទីរចំនួន ៦៨លិខិត

**+ការងារផែនការ**

- រៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២៣-២០២៥ ផ្ញើទៅក្រសួងអភិវឌ្ឍន៍ជនបទ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបន្ទាយមានជ័យ

- រៀបចំផែនការថវិកាកម្មវិធី ប្រចាំឆ្នាំ២០២៣

- រៀបចំរបាយការណ៍៥ឆ្នាំ (ឆ្នាំ២០១៨-២០២២) ជូនរដ្ឋបាលខេត្ត

- រៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលឆ្នាំ២០២៣-២០២៥។

- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាសទី១ ឆមាស ៩ខែនិងប្រចាំឆ្នាំ (ជូនក្រសួងអភិវឌ្ឍន៍ជនបទ)

- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាសទី១ ឆមាស ៩ខែនិងប្រចាំឆ្នាំ (តាមគំរូរដ្ឋបាលខេត្ត)

**+ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ**

ក្នុងឆ្នាំ២០២២ នេះមន្ទីរទទួលបានឥណទានសរុប១,៨៣៨,៤០០,០០០រៀល អនុវត្តបាន ១,៧៧០,៦៨១,០៩៣រៀល ស្មើនឹង៩៦,៣៧% ក្នុងនោះមានៈ

- ជំពូក៦០ (ការទិញ) មានឥណទានសរុប ២០៦,៣០០,០០០រៀល អនុវត្តបាន ១៨១,០៨១,០០០រៀល ស្មើនឹង៨៨%

- ជំពូក៦១ (សេវាកម្ម) មានឥណទានសរុប ១,០២១,១០០,០០០រៀល អនុវត្តបាន ៩៩៧,៤៩៩,៥៧៣រៀល ស្មើនឹង៩៧.៦៩%

- ជំពូក៦៤ (បន្ទុកបុគ្គលិក) ឥណទាន ៦១០,០០០,០០០រៀល អនុវត្តបាន ៥៩២,៣០០,០០០រៀល ស្មើនឹង៩៧.១%

- ជំពូក៦៣ (ពន្ធ និងអាករ) មានឥណទានសរុប ១,០០០,០០០រៀល អនុវត្តបាន ៨០០,០០០រៀល ស្មើនឹង៨០%

**+ការងារសវនកម្ម**

- ការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំមន្ទីរអភិវឌ្ឍន៍ជនបទឆ្នាំ២០២០១

- របាយការណ៍សម្រេចទូទាត់ថវិការរបស់មន្ទីរឆ្នាំ២០២១

- ដីការស្តីពីកាតែងតាំងរដ្ឋទេយ្យករចំណូល រដ្ឋទេយ្យបុរេប្រទាន និងភ្នាក់ងារបើកផ្តល់

- បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២០ និងតារាងប្រៀបធៀបស្តីពីការកើនឡើង និងថយចុះនៃទ្រព្យសម្បត្តិរបស់រដ្ឋឆ្នាំ២០២១

- កំណត់ហេតុអធិការកិច្ចនិងសវនកម្មផ្ទៃក្នុងឆ្នាំ២០២០ និង២០២១

- សំណុំឯកសារលទ្ធកម្មរបស់មន្ទីរឆ្នាំ២០២១ (បញ្ជីប៉ាន់តម្លៃ កិច្ចសន្យា កំណត់ហេតុប្រគល់ទទួល និងអាណត្តិបើកប្រាក់)

- របាយការណ៍បូកសរុបការងារឆ្នាំ២០២១ និងទិសដៅអនុវត្តឆ្នាំ២០២២

- សម្រង់អាណត្តិឆ្នា២០២១

- បញ្ជីបេឡាឆ្នាំ២០២១ និងតារាងបង្កើតរដ្ឋទេយ្យឆ្នាំ២០២១

- កំណត់ហេតុរដ្ឋទេយ្យតាមជុំនីមួយៗឆ្នាំ២០២១

- ផែនការលទ្ធកម្មប្រចាំឆ្នាំ កែតម្រូវ របាយការណ៍លទ្ធកម្មឆ្នាំ២០២១

- ប្រកាសស្តីពីការបង្កើតក្រុមលទ្ធកម្ម

- របាយការណ៍ចំណាយប្រចាំឆ្នាំនៃការអនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពប្រចាំឆ្នាំ ២០២១

- របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ២០២១

- ការចុះបញ្ជីសារពើភណ្ឌផ្លូវលំ

- ឯកសារពាក់ព័ន្ធផ្សេងៗ

**+ការងារអធិការកិច្ច**

- ការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំមន្ទីរអភិវឌ្ឍន៍ជនបទឆ្នាំ២០២១

- របាយការណ៍សម្រេចទូទាត់ថវិការបស់មន្ទីរឆ្នាំ២០២១

- ដីការស្តីពីការតែងតាំងរដ្ឋទេយ្យករចំណូល រដ្ឋទេយ្យបុរេប្រទាន និងភ្នាក់ងារបើកផ្តល់

- បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២០ និងតារាងប្រៀបធៀបស្តីពីការកើនឡើង និងថយចុះនៃទ្រព្យសម្បត្តិរបស់រដ្ឋឆ្នាំ២០២១

- កំណត់ហេតុអធិការកិច្ចនិងសវនកម្មផ្ទៃក្នុងឆ្នាំ២០១៩ និង២០២១

- សំណុំឯកសារលទ្ធកម្មរបស់មន្ទីរឆ្នាំ២០២១ (បញ្ជីប៉ាន់តម្លៃ កិច្ចសន្យា កំណត់ហេតុប្រគល់ទទួល និងអាណត្តិបើកប្រាក់)

- របាយការណ៍បូកសរុបការងារឆ្នាំ២០២១ និងទិសដៅអនុវត្តឆ្នាំ២០២២

- ផែនការលទ្ធកម្មប្រចាំឆ្នាំ កែតម្រូវ របាយការណ៍លទ្ធកម្មឆ្នាំ២០២១

- របាយការណ៍ចំណាយប្រចាំឆ្នាំនៃការអនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពប្រចាំឆ្នាំ ២០២១

- របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ២០២១

- ឯកសារពាក់ព័ន្ធផ្សេងៗ

**+ការងារយេនឌ័រ**

- ចូលរួមប្រជុំស្តីពីស្ត្រី និងកុមារចំនួន ៤លើក

**២.ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍**

**+ការងាររៀបចំបញ្ជីសារពើភ័ណ្ឌ និងទិន្នន័យផ្លូវជនបទ**

ចុះស្រង់ទិន្នន័យ និងធ្វើបច្ចុប្បន្នភាពខ្សែផ្លូវសរុប ១៧១ខ្សែ មានប្រវែង ៧២៧,៤១៣ ម៉ែត្រ នៅស្រុកម៉ា-ឡៃ ស្វាយចេក ព្រះនេត្រព្រះ មង្គលបូរី ក្រុងប៉ោយប៉ែត និងក្រុងសិរីសោភ័ណ

**+ការងាររាប់ចរាចរណ៍យានយន្ត**

- រាប់ចំនួនចរាចរណ៍យានយន្ត១០ខ្សែ នៅស្រុកម៉ាឡៃ ព្រះនេត្រព្រះ មង្គលបូរី អូរជ្រៅ និងក្រុងប៉ោយប៉ែត

**+ការងារជួសជុលផ្លូវជនបទ និងសំណង់សិល្បការ្យ**

- ជួសជុលផ្លូវកម្រាលក្រួសក្រហម ២ខ្សែ ប្រវែង ៨,៤០០ម៉ែត្រ និងដាក់លូមូល ៣កន្លែង នៅស្រុកភ្នំស្រុក

**+ការថែទាំផ្លូវទប់ទល់នឹងបម្រែបម្រួលអាកាសធាតុ (ដាំកូនឈើតាមផ្លូវជនបទ)**

- ដាំកូនឈើបាន១,០០០ដើម នៅផ្លូវវ៉ាសុភី ឃុំសូភី ស្រុកអូរជ្រៅ

**៣.ការងារកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ**

**+ការងារសាងសង់អណ្តូងទឹកធន់នឹងការប្រែប្រួលអាកាសធាតុ**

- សាងសង់អណ្តូងស្នប់ចំនួន ២អណ្តូងនៅស្រុកព្រះនេត្រព្រះ និងស្រុកភ្នំស្រុក

**+ការងារសាងសង់អណ្តូងទឹក ប្រភពទឹក និងហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតជនបទចម្រុះ**

- សាងសង់ស្ថានីយ៍ចែកចាយទឹកស្អាត ១កន្លែង និងឃុំបន្ទាយឆ្មារ ស្រុកថ្មពួក

**+ការងារអប់រំប្រជាពលរដ្ឋ អំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាត**

- ផ្សព្វផ្សាយ និងជំរុញការប្រើប្រាស់ និងបរិភោគទឹកស្អាតដោយសុវត្ថិភាពចំនួន ៥លើក នៅស្រុកថ្មពួក ភ្នំស្រុក និងស្រុកស្វាយចេក

**+ការងារស្រង់ទិន្នន័យបង្គន់អនាម័យជនបទ**

- ប្រមូលទិន្នន័យបង្គន់អនាម័យជនបទទូទាំងខេត្ត សម្រេចបានលទ្ធផល១០០%

**+ការងារលើកកម្ពស់ការផ្លាស់ប្តូរទម្លាប់ ឲ្យមានការរស់នៅស្អាត និងមានអនាម័យនៅជនបទ**

- បណ្តុះបណ្តាលក្រុមគណៈកម្មការពិនិត្យ និងផ្ទៀងផ្ទាត់ភូមិបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាលបានចំនួន ៥លើក នៅស្រុកព្រះនេត្រព្រះ

- បានចែកសម្ភារទឹកស្អាត និងអនាម័យតាមទីទួលសុវត្ថិភាព នៅស្រុកមង្គលបូរី និងក្រុងសិរីសោភ័ណ

**៤.ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ**

**+ការងារលើកកម្ពស់កំណើនសេដ្ឋកិច្ចគ្រួសារនៅជនបទ**

- ផ្តល់ប្រាក់កម្ចីសរុបចំនួន ៣៣០,០០០,០០០៛ ដល់សមាជិកសរុបចំនួន៣៣៦នាក់ ស្រីចំនួន ២៥១នាក់ ( សមាជិកខ្ចីប្រាក់គម្រោង RACHA )

-ផ្សព្វផ្សាយ និងបង្កើនឥណទានជនបទចំនួន ៤លើក អ្នកចូលរួមមានចំនួន ៣៥៥នាក់ ស្រី ២៩០នាក់ នៅស្រុកអូរជ្រៅ

-ចុះស្រាវជ្រាវតម្រូវការទីផ្សារក្នុងសហគមន៍មូលដ្ឋានចំនួន ៥លើក អ្នកចូលរួមមានចំនួន ២៩៣នាក់ ស្រីចំនួន ២១៤នាក់ នៅស្រុកស្វាយចេក

**+ការងារអភិវឌ្ឍន៍ និងអភិរក្សជនជាតិដើមភាគតិច**

- ធ្វើបច្ចុប្បន្នភាពជនជាតិដើមភាគតិច នៅឃុំជប់វារី ស្រុកព្រះនេត្រព្រះ មានចំនួន ៥០៦ គ្រួសារ មនុស្សរាយចំនួន ២,៣០៨នាក់ ស្រីចំនួន ១,១៥២នាក់

- ប្រារព្ធទិវាជនជាតិភាគតិច ចំនួន ១លើក នៅឃុំជប់វារី ស្រុកព្រះនេត្រព្រះ

**៥.សមិទ្ធផលនៃការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការ**

**ក.ការងារសហប្រតិបត្តិការជាមួយនាយកដ្ឋានផ្លូវជនបទ**

- ផ្លូវថែទាំប្រចាំ សរុបចំនួន១១ខ្សែ ប្រវែង១១៧,០០០ម៉ែត្រ ស្ថិតក្នុងស្រុកស្វាយចេក ថ្មពួក ព្រះនេត្រព្រះ និងស្រុកភ្នំស្រុក

- ផ្លូវថែទាំខួប សរុបចំនួន១ខ្សែ ប្រវែង១៣,០០០ម៉ែត្រ នៅឃុំទ្រាស ស្រុកស្វាយចេក

- ជួសជុលផ្លូវជនបទជាលក្ខណៈបន្ទាន់ចំនួន ១ខ្សែ ប្រវែង២,០៥០ម៉ែត្រ នៅឃុំថ្មពួក ស្រុកថ្មពួក

**ខ.គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងគាំទ្រកសិករ**

-សាងសង់ផ្លូវក្រាសក្រួសក្រហមចំនួន ១៤ខ្សែ មានប្រវែង ៧៨,៣២៦ម៉ែត្រ នៅស្រុកថ្មពួក ស្វាយចេក និងក្រុងសិរីសោភ័ណ

-សាងសង់ផ្លូវដីសចំនួន ៤៨ខ្សែ មានប្រវែង ៨៣,៨០០ម៉ែត្រ ស្រុកថ្មពួក ស្វាយចេក ភ្នំស្រុក និង ក្រុងសិរីសោភ័ណ

**គ.គម្រោងផ្គត់ផ្គង់ទឹកជនបទ និងអនាម័យដំណាក់កាល ៣ (ហិរញ្ញប្បទានបន្ថែម ADB Loan)**

- ផ្តល់សម្ភារសាងសង់បង្គន់អនាម័យតាមគ្រួសារ ចំនួន ២៨២ខ្នងផ្ទះ នៅឃុំរហាត់ទឹក ស្រុកមង្គលបូរី
- ផ្តល់ពាងត្រង់ទឹកភ្លៀងចំណុះ១ម៉ែត្រគូប ចំនួន៤,៩៨០ពាង នៅស្រុកមង្គលបូរី
- សាងសង់អណ្តូងស្នប់ចំនួន ៧៦អណ្តូង នៅស្រុកមង្គលបូរី
- សាងសង់ស្ថានីយស្រូបទឹកពីបរិយាកាស ០១ កន្លែង នៅឃុំតាគង់ ស្រុកម៉ាឡៃ

**II.បញ្ហាប្រឈម**

- តម្រូវការសម្រាប់ការអភិវឌ្ឍច្រើន ថវិកាគាំទ្រនៅមានកម្រិត
- ខ្វះការចូលរួមថែទាំសមិទ្ធផលនានារបស់វិស័យអភិវឌ្ឍន៍ជនបទ
- ប្រជាពលរដ្ឋមួយចំនួនមិនទាន់យល់ពីអនាម័យ និងធ្វើការផ្លាស់ប្តូទំលាប់
- ប្រជាជនធ្វើចំណាកស្រុកច្រើន
- ខ្វះមន្រ្តីក្នុងការអនុវត្តការងារ
- ផ្លូវជនបទរងការខូចខាតដោយសារគ្រោះទឹកជំនន់ច្រើនជារៀងរាល់ឆ្នាំ
- ប្រជាជនជនបទនៅស្ទើរទូទាំងខេត្តបន្ទាយមានជ័យខ្វះខាតផ្លូវក្រាលកៅស៊ូ និងផ្លូវបេតុង
- ប្រជាពលរដ្ឋត្រូវការបណ្តុះបណ្តាលជំនាញ វិជ្ជាជីវៈមូលដ្ឋាន
- ប្រជាពលរដ្ឋត្រូវការឥណទានដើម្បីបង្កើនមុខរបរ

**III.ទិសដៅការងារឆ្នាំ២០២៣**

**១.ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាព**

**+ការងាររដ្ឋបាល និងបុគ្គលិក**

- ការគ្រប់គ្រងការងាររដ្ឋបាល និងបុគ្គលិកឲ្យកាន់តែប្រសើរឡើង ប្រកបដោយការទទួលខុសត្រូវខ្ពស់
- ការគ្រប់គ្រងវត្តមានជាប្រចាំថ្ងៃ និងមានវិធានការច្បាស់លាស់ចំពោះមន្រ្តីដែលអវត្តមាន
- រៀបចំ និងទុកដាក់ឯកសារក្នុងការិយាល័យរដ្ឋបាលឲ្យមានរបៀបរៀបរយ និងងាយស្រួល
- ការងាររៀបចំផ្លាស់ប្តូរស្ថានភាពមន្រ្តីរាជការដែលបានដំឡើងថ្នាក់ ឋានន្តរស័ក្តថ្នាក់ ការផ្លាស់ប្តូរមុខតំណែង ការបញ្ចូលកូន/ប្រពន្ធ ជូនមន្រ្តីរាជការឲ្យបានទាន់ពេលវេលា
- ពិនិត្យការដំឡើងថ្នាក់ជូនមន្រ្តីរាជការស្របតាមគោលការណ៍ណែនាំរបស់ក្រសួង
- រៀបចំការលើកទឹកចិត្តមន្ត្រីតាមរយៈ ការផ្តល់តួនាទី និងគ្រឿងឥស្សរិយយសប្រចាំឆ្នាំចំពោះ មន្ត្រីរាជការណាដែលបានខិតខំ និងអនុវត្តតួនាទីភារកិច្ចល្អជាងគេ
- ពង្រឹងសាមគ្គីភាពផ្ទៃក្នុងឲ្យកាន់តែល្អ និងយោគយល់គ្នាក្នុងអង្គភាព

**+ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងអប់រំផ្សព្វផ្សាយ ដល់មន្រ្តីរាជការ**

- រៀបចំរបាយការណ៍បណ្តុះបណ្តាល និងសិក្ខាសាលាប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ទៅនាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវ ឲ្យកាន់តែច្បាស់លាស់ និងការទទួលខុសត្រូវខ្ពស់

- ពង្រឹងការងាររបស់មជ្ឈមណ្ឌលឲ្យកាន់តែប្រសើរឡើង

- ពង្រឹង និងបណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីរាជការ

**+ការងារផែនការ**

- រៀបចំបូកសរុបរបាយការណ៍វឌ្ឍនភាពរបស់មន្ទីរស្តីពីការអនុវត្តសកម្មភាព ជាប្រចាំខែត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំ

- ចូលរួមរៀបចំផែនការថវិកាកម្មវិធី ផែនការយុទ្ធសាស្ត្រថវិកា ផែនការវិនិយោគបីឆ្នាំរំកិលថ្នាក់ស្រុក

- តាមដានត្រួតពិនិត្យលើការអនុវត្តរបស់ការិយាល័យនីមួយៗ ដែលបានអនុវត្តផែនការថវិកាកម្មវិធីឲ្យមានប្រសិទ្ធភាព

- ចូលរួមកិច្ចប្រជុំផ្សេងៗជាមួយរដ្ឋបាលខេត្ត លើការរៀបចំផែនការវិនិយោគបីឆ្នាំរំកិលរបស់ខេត្តបន្ទាយមានជ័យ

**+ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ**

- បន្តរៀបចំប្រាក់បៀវត្ស និងបេសកកម្មដល់មន្ត្រីរាជការ

- រៀបចំរបាយការណ៍ប្រចាំខែ ,ត្រីមាស, ឆមាស និងប្រចាំឆ្នាំ ជូនការិយាល័យជំនាញ

- រៀបចំ និងសម្របសម្រួលជំពូកថវិកា និងរាល់ការចំណាយរបស់មន្ទីរឲ្យមានប្រសិទ្ធភាពខ្ពស់

- កសាងផែនកាចំណូលចំណាយតាមច្បាប់ហិរញ្ញវត្ថុ

- ត្រួតពិនិត្យបញ្ជីចំណូលចំណាយត្រឹមត្រូវតាមទម្រង់បែបបទគណនេយ្យ

- លើកគម្រោងថវិការបស់មន្ទីរ ធ្វើកម្មវិធីចំណាយ និងតាមដានរំលឹកពីការប្រតិបត្តិការ

- ផ្គត់ផ្គង់ផ្នែកសម្ភារៈជូនដល់បណ្តាការិយាល័យចំណុះមន្ទីរ

- គ្រប់គ្រងបែងចែកសម្ភារៈ និងមធ្យោបាយដឹកជញ្ជូន

- រៀបចំសំណើថវិកា និងរបាយការណ៍ចំណូលចំណាយ

- គ្រប់គ្រងនិងត្រួតពិនិត្យធ្វើបញ្ជីសារពើភណ្ឌទ្រព្យរដ្ឋ

- ធ្វើកម្មវិធីបែងចែកថវិកា ប្រេងឥន្ធនៈ គ្រឿងបន្លាស់សម្រាប់យានយន្តរបស់រដ្ឋ

- គ្រប់គ្រងជួសជុលសម្ភារៈ និងបរិក្ខាររបស់មន្ទីរ

- សហការឲ្យកាន់តែល្អប្រសើរជាមួយមន្ត្រីក្នុងអង្គភាព និងក្រៅអង្គភាព

**+ការងារយេនឌ័រ**

ពង្រឹងការងារយេនឌ័រក្នុងវិស័យអភិវឌ្ឍន៍ជនបទ តាមរយៈការផ្តល់ឱកាសឲ្យជនបង្គោលទទួលបានការបណ្តុះបណ្តាល និងតាមរយៈផ្សព្វផ្សាយការងារឲ្យបានច្រើនដល់ស្ត្រី និងកុមារ ជាពិសេសជនងាយរងគ្រោះ។

## ២.ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍

**+ការងាររៀបចំបញ្ជីសារពើភ័ណ្ឌ និងទិន្នន័យផ្លូវជនបទ**

- ចុះស្រង់ទិន្នន័យ និងធ្វើបច្ចុប្បន្នភាពខ្សែផ្លូវសរុប ១២៥ខ្សែ នៅស្រុកថ្មពួក ម៉ាឡៃ ភ្នំស្រុក ស្វាយចេក អូរជ្រៅ ព្រះនេត្រព្រះ មង្គលបូរី ក្រុងប៉ោយប៉ែត និងក្រុងសិរីសោភណ័។

**+ការងាររាប់ចរាចរណ៍យានយន្ត**

- ការរាប់ចំនួនចរាចរណ៍យានយន្ត១០ខ្សែ នៅស្រុកស្វាយចេក ព្រះនេត្រព្រះ និងស្រុកភ្នំស្រុក

**+ការងារថែទាំផ្លូវជនបទ និងសំណង់សិល្បការ្យ**

- បន្តថែទាំផ្លូវជនបទចំនួន ០២ខ្សែ ផ្លូវក្រាលក្រួសក្រហមទទឹង ៥ម ប្រវែង៧,១០០ម៉ែត្រ នៅឃុំ ពន្លៃ ស្រុកភ្នំស្រុក

**+ការថែទាំផ្លូវទប់ទល់នឹងបម្រែបម្រួលអាកាសធាតុ (ដាំកូនឈើតាមផ្លូវជនបទ)**

- ដាំកូនឈើ ១០០០ដើម នៅឃុំសូភី ស្រុកអូរជ្រៅ

## ៣.ការងារកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ

**+ការងារសាងសង់អណ្តូងទឹកធន់នឹងការប្រែប្រួលអាកាសធាតុ**

- សាងសង់អណ្តូងស្នប់ចំនួន ៥អណ្តូង នៅក្រុងសិរីសោភ័ណ និងស្រុកព្រះនេត្រព្រះ

**+ការងារអណ្តូងទឹកស្អាត ប្រភពទឹក និងហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតជនបទចម្រុះ**

- សាងសង់ស្ថានីយចែកចាយទឹកស្អាត ១កន្លែង នៅស្រុកថ្មពួក

**+ការងារអប់រំប្រជាពលរដ្ឋ អំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាត**

- ធ្វើការផ្សព្វផ្សាយការប្រើប្រាស់ បរិភោគទឹកស្អាតដោយសុវត្ថិភាព ចំនួន៤លើក នៅស្រុក ភ្នំស្រុក ថ្មពួក និងស្រុកស្វាយចេក

**+ការងារប្រារព្ធទិវាលាងសម្អាតដៃពិភពលោកតាមខេត្ត**

- រៀបចំទិវាលាងសម្អាតដៃពិភពលោក ចំនួន ០១លើក ក្នុងព្រះនេត្រព្រះ

**+ការងារលើកកម្ពស់ការផ្លាស់ប្តូរទម្លាប់ឲ្យមានការរស់នៅស្អាត និងមានអនាម័យនៅជនបទ**

- ចុះពិនិត្យផ្ទៀងផ្ទាត់ និងវាយតម្លៃភូមិដែលបានឈប់បន្ទោបង់ពាសវាលពាសកាល នៅតាមភូមិ ចំនួន៥លើក នៅស្រុកម៉ាឡៃ

**+ការងារស្រង់ទិន្នន័យបង្គន់អនាម័យជនបទ**

- ស្រង់ទិន្នន័យបង្គន់អនាម័យជនបទ ទូទាំងខេត្ត

## ៤.ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ

**+ការងារលើកកម្ពស់ និងបង្កើតមុខរបរនៅជនបទ**

- បន្តធ្វើកិច្ចសហការល្អជាមួយអង្គការដៃគូឲ្យបានល្អ លើការងារលើកកម្ពស់ និងជួយរកមុខរបរ អាជីវកម្ម ជូនប្រជាពលរដ្ឋនៅតំបន់មូលដ្ឋាន។

- ចុះសិក្សាពីតម្រូវការទីផ្សារសហគមន៍មូលដ្ឋាន ចំនួន៦លើក នៅស្រុកព្រះនេត្រព្រះ

**+ការលើកកម្ពស់កំណើនសេដ្ឋកិច្ចគ្រួសារនៅជនបទ**

- គាំទ្រនិងតាមដានដល់សកម្មភាពរបស់អង្គការដៃគូលើការងារឥណទានសន្សំប្រាក់នៅសហ គមន៍ ដើម្បីបង្កើនជីវភាព

- តាមដាន និងសម្របសម្រួលការងារឥណទានសន្សំប្រាក់របស់សហគមន៍ដែលបានទទួល ស្គាល់ដោយមន្ទីរអភិវឌ្ឍន៍ជនបទខេត្តបន្ទាយមានជ័យ

- ចុះផ្សព្វផ្សាយ និងបង្កើនឥណទានជនបទ និងចុះប្រមូលទិន្នន័យក្រុមសន្សំសហគមន៍ ចំនួន ៤លើក នៅស្រុកភ្នំស្រុក

+ការងារអភិវឌ្ឍន៍ និងអភិរក្សជនជាតិដើមភាគតិច

- ធ្វើបច្ចុប្បន្នភាពជនជាតិដើមភាគតិច នៅឃុំជប់វារី ស្រុកព្រះនេត្រព្រះ
- ប្រារព្វទិវាជនជាតិដើមភាគតិច នៅឃុំជប់វារី ស្រុកព្រះនេត្រព្រះ

**៥.សមិទ្ធផលនៃការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការ**

+ការងារសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន និងអង្គការដៃគូរជាតិ

- បន្តអនុវត្តគម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជំហានទី៤
- គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងគាំទ្រកសិករ
- ថែទាំផ្លូវលក្ខណៈខួបចំនួន ០១ខ្សែ ប្រវែង១៦,៦០០ម៉ែត្រ នៅស្រុកព្រះនេត្រព្រះ
- ថែទាំផ្លូវលក្ខណៈប្រចាំចំនួន ១០ខ្សែ ប្រវែង ១២១,៨០០ម៉ែត្រ នៅស្រុកថ្មពួក ព្រះនេត្រព្រះ ស្វាយចេក អូរជ្រៅ និងស្រុកភ្នំស្រុក

**សេចក្តីសន្និដ្ឋាន**

យោងទៅលើសមិទ្ធផលដែលមន្ទីរអភិវឌ្ឍន៍ជនបទសម្រេចបានក្នុងអណត្តិទី៤ នៃក្រុមប្រឹក្សាខេត្ត ឆ្នាំ២០១៩-២០២៤ វិស័យអភិវឌ្ឍន៍ជនបទក្នុងខេត្តបន្ទាយមានជ័យបាននឹងកំពុងរីកចម្រើនទៅមុខជាលំដាប់គ្រប់ផ្នែកទាំងអស់រួមមានហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ការអភិវឌ្ឍសហគមន៍ និងសេដ្ឋកិច្ចជនបទ បានធ្វើឲ្យកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់តែល្អប្រសើរ។ លើសពីនេះទៅទៀតបានចូលរួមកាត់បន្ថយគម្លាតពីទីជនបទ ឲ្យមកខិតជិតទីប្រជុំជនស្របតាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្រោមការដឹកនាំរបស់ **សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋក្នុងតំបន់។ ដូច្នេះមន្ទីរអភិវឌ្ឍន៍ជនបទខេត្តបន្ទាយមានជ័យនឹងបន្តខិតខំព្យាយាមបន្ថែមទៀតចំពោះផែនការដែលបានដាក់ចេញសម្រាប់អនុវត្តការងារក្នុងឆ្នាំ២០២២ ឲ្យកាន់តែមានប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់។

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័កព.ស.២៥៦៦

បន្ទាយមានជ័យ, ថ្ងៃទី ខែ ឆ្នាំ២០២២

**ប្រធានមន្ទីរ**